# កុំកាន់សាសនាឲ្យជ្រុល

( ទំព័រ៥៥ )

កុំកាន់សាសនា ឲ្យជ្រុលជ្រុស
ហួសដល់ជាតិស្លាប់ក៏មិនគិត
ស្មានថា ខ្លួនឯងជាបណ្ឌិត
តែពិតជាល្ងិត ពាលសោះទេ។

ព្រះពុទ្ធឲ្យធ្វើប្រយោជន៍ពីរ
គឺប្រយោជន៍ខ្លួន ប្រយោជន៍គេ
ម្តេចអ្នកមិនចេះគិតគ្នាន់គ្នេរ
រេគិតធ្វើតែប្រយោជន៍ខ្លួន។

ជាតិមានទុក្ខធំមិនជួយកែ
បែរកាន់សាសនាបែបមាំមួន
ទុកឲ្យជាតិស្លាប់ដោយសៀមយួន
ហ្នឹងពិតជាខ្លួនពាលពេញទី។

* * *

មានះ អួតអាង ថាគ្រាន់បើ
វាមិនប្រសើរទេអ្នកអើយ !
នាំឲ្យកើតទុក្ខឥតមានស្បើយ
បើអ្នកយល់ហើយ ត្រូវលះចេញ។

( ទំព័រ៥៨ )

* * *

# កុំកាន់សាសនាភ្លេចប្រពន្ធកូន

(ទំព័រ៩៦)

កុំកាន់សាសនា    ភ្លេចប្រពន្ធ កូន
ភ្លេចបង ភ្លេចប្អូន    ភ្លេចឪពុក ម្ដាយ
ភ្លេចប្រទេសជាតិ    ជាទីអាស្រ័យ
ហៅសែនចង្រៃ    ព្រោះតែកាន់ខុស។
កុំប្រកាន់បក្ស    ដល់ថ្នាក់ភ្លេចជាតិ
ជាតិស្លាប់ៗ ចុះ    ឲ្យតែបក្សរស់
បើបក្សយើងឈ្នះ    យើងបានធំខ្ពស់
ពួកយើងនឹងរស់    ជញ្ជក់ឈាមទៀត។
ជាតិស្លាប់ បក្សរស់    នៅយូរម៉េចបាន
គង់តែធ្លាក់ប្រាណ    ខ្ញុំគេបោលម្សៀត
អាប់មុខ ទុក្ខក្ដៅ    ព្រោះតែមារយាទ
លើកបក្សជាងជាតិ    បានជាអន្តរាយ។
ជាតិស្លាប់ៗ ចុះ    ឲ្យតែយើងមាន
បានទ្រព្យធនធាន    មាស ពេជ្រ ប្រាក់ បាយ
លក់ជាតិ គ្រឿងញៀន    អាភៀន អបាយ
អ្នកលក់ជិតឆ្ងាយ    ក្លែងក្លាយតាមចិត្ត។
ចូរយើងចាំមុខ    ពួកខ្មែរចិត្តខ្មាំង
ដល់ពេលជ្រើសតាំង    យើងកុំអាណិត
ទម្លាក់វាចោល    កុំឲ្យវាស្ថិត
នៅធ្វើធំទៀត    បំផ្លាញជាតិយើង។

* * *

# ចង់សុខសប្បាយក្នុងស្ថានសួគ៌

(ក្របក្រោយ)

ចង់សុខសប្បាយក្នុងស្ថានសួគ៌ មិនបានគិតគូរដល់ជាតិនេះ
រវល់ធ្វើបុណ្យ ភ្លេចត្រិះរិះ មិនដឹងជាតិនេះទុក្ខអ្វីខ្លះ។
ទុក្ខនៅប្រចាំ គ្រប់អាត្មា កើតមានរូបាត្រូវតែចាស់
ឈឺចាប់ និងស្លាប់ប្រាកដណាស់ បាក់បែកព្រាត់ប្រាសជាធម្មតា។
ទុក្ខក្រៅពីនេះ មានច្រើនទៀត ម្តេចអ្នកមិនឆ្លៀតពិចារណា
ទុក្ខអស់ទឹកដីស្រែចម្ការ អស់កម្ពុជាពូជពង្សខ្មែរ។
ទុក្ខព្រោះអស់សិទ្ធិសេរីភាព ធ្លាក់ខ្លួនជោកទាបអន់ជាងឆ្កែ
យួនចូលរុករានឥតមានល្ហែ ជញ្ជក់ឈាមខ្មែរសោះអស់ហើយ។
រត់បោលកូនចៅ ទៅស្ថានសួគ៌ ជាការមិនគួរសមសោះឡើយ។
កូនចៅរងទុក្ខ ពុំមានស្បើយ អំពើហ្នឹងហើយឬ ជាល្អ
នាំគ្នាប្រមាទ មិនដោះស្រាយ ហើយខំសប្បាយថា បានធម៌។
នាំតែអស់បាយ អស់សម្ល ពួកអ្នករៀនធម៌ ហើយបិទភ្នែក
ចាប់បើកភ្នែកមើលឥឡូវហ្នឹង ត្រូវតែយល់ដឹង កុំចាំស្អែក។
នាំគ្នាដោះស្រាយឈប់បាក់បែក ឈប់នាំជជែករករឿងឈ្លោះ។
នាំគ្នាដេញយួនឲ្យចេញទៅ កុំឲ្យវានៅនាំមានគ្រោះ
ជាតិយើង បាត់បង់កិត្តិយស កើតទុក្ខ ពីព្រោះយួននេះអែង។
នាំគ្នាសាងជាតិ និងសាសនា ឲ្យបានថ្លៃថ្លាភ្លឺចិញ្ចែង
ពឹងលើកម្លាំងខ្មែរគ្នាឯង ខ្មែរយើងខែងរ៉ែងមិនចាញ់គេ។
ខ្មែរនឹងសប្បាយ ដូចស្ថានសួគ៌ មិនអន់អាប់អួរដូចនេះទេ
ព្រោះយើងម្ចាស់ស្រុកពិតស្ថិតស្ថេរ ស្មើមុខដូចគេអង្វែងទៅ។

**ហីនយាន មហាយាន**

*ដោយ ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ*

*បោះពុម្ពឆ្នាំ២០០៧ ប្រទេសបារាំង*